# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

## សេចក្តីប្រកាសព័ត៌មាន

------------

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសរសេរលិខិតមួយច្បាប់កាលពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៧ ផ្ញើជូនឯកឧត្តម Ahmet Üzümcü អគ្គនាយកនៃអង្គការហាមឃាត់អាវុធគីមី ( Organization for the Prohibition of Chemical Weapons - OPCW ) ដែលមានទីស្នាក់ការ នៅទីក្រុងឡាអេ (The Hague) ប្រទេសហូឡង់ ដើម្បីជម្រាបជូនពីការរកឃើញអាវុធគីមីនៅកម្ពុជា និងស្វែងរកជំនួយរបស់អង្គការហាមឃាត់អាវុធគីមី ក្នុងបញ្ហានេះ។

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានលើកឡើងក្នុងលិខិតរបស់ឯកឧត្តមថា៖

"ខ្ញុំសូមជម្រាបឯកឧត្តមថា នៅក្នុងប្រតិបត្តិការបោសសំអាតមីន និងកាកសំណល់សង្គ្រាម ដែលមានផលប៉ះពាល់តំបន់ជាច្រើននៃផ្ទៃប្រទេស កម្ពុជាបានប្រទះឃើញអាវុធគីមីមួយចំនួន។ កាលពីខែមីនា និងមេសា ឆ្នាំ២០១២ អ្នកជំនាញមកពីអង្គការហាមឃាត់អាវុធគីមី បានពិនិត្យ និងបញ្ជាក់វត្តមាននៃអាវុធគីមី ដែលត្រូវបានរកឃើញនៅខេត្តមណ្ឌលគីរី។ នៅដើមខែតុលា ឆ្នាំ២០១៧ថ្មីៗនេះ យើងបានយកចេញកាកសំណល់អាវុធមួយចំនួន ពីសាលាបឋមសិក្សាគគីរ និងវត្ត ក្នុងឃុំគគីរ ខេត្តស្វាយរៀង ដែលក្រោយមកត្រូវបានបញ្ជាក់ដោយអ្នកជំនាញពីអាជ្ញាធរជាតិអាវុធគីមី ( NACW ) និងមជ្ឈមណ្ឌលជាតិកម្ចាត់មីនកម្ពុជា ( CMAC ) ថាសារធាតុដែលរកឃើញនៅក្នុងអាវុធទាំងនោះ ស៊ីគ្នាទៅនឹងនិយមន័យអាវុធគីមី ចែងក្នុងមាត្រា II កឋាខណ្ឌ១ (១) និង (b) នៃអនុសញ្ញាស្តីពីអាវុធគីមី។ នៅក្នុងឃុំ គេពិនិត្យឃើញមានជនរងគ្រោះមួយចំនួនផងដែរ។

"មកដល់សព្វថ្ងៃ មានទីតាំងចំនួន៣៤កន្លែង ដែលត្រូវបានរកឃើញថាមានផ្ទុកអាវុធប្រភេទដូចគ្នានេះ នៅទូទាំងប្រទេសកម្ពុជា។

"អនុលោមតាមមាត្រាIII កឋាខណ្ឌ១ (b) នៃអនុសញ្ញាស្តីពីការហាមឃាត់ ការអភិវឌ្ឍន៍ ការផលិត ការរក្សាទុក ការប្រើប្រាស់ និងការបំផ្លាញចោលអាវុធគីមី ( Convention on the Prohibition of Development, Production, Stockpiling and Use of Chemical

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

Weapons and their Destruction - CWC) ព្រះរាជាណាចក្រកម្ពុជា សូមប្រកាសថា កម្ពុជារងផលប៉ះពាល់ដោយសំណល់អាវុធគីមីពីសង្គ្រាម ប្រើប្រាស់អំឡុងទសវត្សឆ្នាំ ១៩៦០ និង១៩៧០។ ជាមួយគ្នានេះ ដូចដែលឯកឧត្តម បានជ្រាបហើយ អនុសញ្ញា ក៏តម្រូវឲ្យរដ្ឋ ដែលបានប្រើប្រាស់ និងបន្សល់ទុកអាវុធគីមី ធ្វើការប្រកាសផងដែរ។

"ប្រឈមមុខនឹងមហន្តរាយនេះ ដើម្បីជានាសុវត្ថិភាព និងសុខមាលភាពរបស់ប្រជាជនកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា អនុលោមតាមផ្នែក IV (B) កឋាខណ្ឌ៨ នៃអនុសញ្ញា ស្នើសុំជំនួយ ពីអង្គការហាមឃាត់អាវុធគីមី ក្នុងដំណើរការពិនិត្យផ្ទៀងផ្ទាត់ គ្រឿងផ្ទុះទាំងអស់នៅតាមទីតាំង ដែលបានស្គាល់រួចហើយ និងជំនួយដើម្បីគាំទ្រដល់ការស្រាវជ្រាវបន្ថែមទៀតអំពីផលប៉ះពាល់នៃ អាវុធគីមី ព្រមទាំងការបោសសំអាត និងការបំផ្លាញអាវុធទាំងនេះ នៅថ្ងៃអនាគត។

"ក្នុងឋានៈជារដ្ឋភាគីនៃអនុសញ្ញា រាជរដ្ឋាភិបាលកម្ពុជា សូមបញ្ជាក់ជាថ្មីពីការបន្តប្តេជ្ញាចិត្ត និង គាំទ្រដល់កិច្ចការងាររបស់អង្គការហាមឃាត់អាវុធគីមី ក្នុងកិច្ចខិតខំប្រឹងប្រែងរួមដើម្បីបំពេញ ភារៈកិច្ច និងកាតព្វកិច្ច តាមការកំណត់របស់អនុសញ្ញានេះ។"

ភ្នំពេញ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧